ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខៈ ៧៧
ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩
សាលដីកា
លេខៈ ៤៣ "V"
ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម៖

១.លោក [redacted] ប្រធាន

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រមរបាយការណ៍

៤.លោក [redacted] ចៅក្រម

៥.លោក [redacted] ចៅក្រម

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

## តំណាងមហាអយ្យការ

ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ៣៣៧ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់លោក[redacted] មូស្សេន្នី ជាមេធាវីការពារសិទ្ធិជនត្រូវចោទឈ្មោះ [redacted] PAUL MULROY ចំពោះសាលដីកាព្រហ្មទណ្ឌលេខ៧២ ស.ស ក្រVII"ធ" ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមាន៖

**ជនត្រូវចោទ** ឈ្មោះ [redacted] PAUL MULROY ភេទប្រុស អាយុ៦៤ឆ្នាំ ជនជាតិខ្មែរ អូស្ត្រាលី កាន់លិខិតឆ្លងដែនលេខPE 0391680 ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥ កើតនៅ LISMORE ប្រទេសអូស្ត្រាលី អាសយដ្ឋានមុនពេលចាប់ខ្លួននៅផ្ទះ [redacted] ខេត្តសៀមរាប កំរិតវប្បធម៌បណ្ឌិត



Scanned with CamScanner

នៅលីវ។ ឪពុកឈ្មោះ [redacted](ស) ម្ដាយឈ្មោះ [redacted](ស)។ (ឃុំខ្លួនតាមដីកាសម្រេចលេខ៩៦៩(ច) /២០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩)។ នៅមន្ទីរឃុំឃាំង ខេត្តសៀមរាប។ (អ្នកប្ដឹងសាទុក្ខ)

-មានមេធាវីការពារសិទ្ធិលោក [redacted]មូស្សេនី ។

<u>ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ:</u> ការទិញពេស្យាចារកុមារ និងអំពើអាសប្រមាំង និងអនិតិជនអាយុក្រោម១៥ឆ្នាំ ប្រព្រឹត្តនៅភូមិបន្ទាយចាស់ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៤ និងមាត្រា៤៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

**អំពីអង្គហេតុ:**

កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩ នៅចំណុចភូមិបន្ទាយចាស់ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កម្លាំងនៃការិយាល័យប្រឆាំងបទល្មើសនិងការពារអនីតិជន បានធ្វើការឃាត់ខ្លួនជនសង្ស័យ ឈ្មោះ [redacted]PAUL MULROY ពាក់ពន្ធ័ទៅនឹងករណីប៉ះពាល់ផ្លូវភេទបំពានទៅលើកុមារចំនួន ០៦(ប្រាំមួយ)នាក់ មានឈ្មោះ [redacted]រ៉ុន ភេទប្រុស អាយុ១១ឆ្នាំ, ឈ្មោះ [redacted]ឡាន់ ភេទប្រុស អាយុ១២ឆ្នាំ,ឈ្មោះ [redacted]តាក់ ភេទប្រុស អាយុ១៤ឆ្នាំ, ឈ្មោះ [redacted]ស៊ីន ភេទប្រុស អាយុ១១ឆ្នាំ, ឈ្មោះ [redacted]ប៊ុនអ៊ីក ភេទប្រុស អាយុ១៤ឆ្នាំ និងឈ្មោះ [redacted]ដែន ភេទប្រុស អាយុ១៣ឆ្នាំ ជាថ្នូរនឹងការផ្តល់ប្រាក់ ដល់ក្រុមគ្រួសាររបស់ជនរងគ្រោះ ព្រមទាំងនាំយកជនរងគ្រោះឱ្យទៅរស់នៅផ្ទះជួលជាមួយកាលពីអំឡុងឆ្នាំ២០១៨។

-បានឃើញ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលេខ ១៣៧៥ "ច" ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ដែលមានខ្លឹមសារដូចតទៅ៖

-ឱ្យឃុំខ្លួនជនត្រូវចោទឈ្មោះ [redacted]PAUL MULRUY ជាបណ្តោះអាសន្ន ហើយយើងនឹងចេញដីកាបង្គាប់ឱ្យឃុំជននេះនៅពន្ធនាគារដើម្បីអនុវត្តការឃុំខ្លួននេះ ។

-បានឃើញដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៩៦៩ "ច" ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ ដែលមានខ្លឹមសារដូចតទៅ៖ដើម្បីធានាការស៊ើបអង្កេតឱ្យបានល្អ៖

បង្គាប់ឲ្យឃុំខ្លួនឈ្មោះ [redacted]PAUL MULROY ភេទប្រុស អាយុ៦៤ឆ្នាំ ជនជាតិអូស្ត្រាលី កាន់លិខិតឆ្លងដែនលេខ PE0391680 ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥ កើតនៅ LISMORE ប្រទេសអូស្ត្រាលី អាសយដ្ឋានបច្ចុប្បន្នស្នាក់នៅផ្ទះជួល[redacted]ខេត្តសៀមរាប កម្រិតវប្បធម៌បណ្ឌិត នៅលីវ ឪពុកឈ្មោះ [redacted]"ស" ម្ដាយឈ្មោះ [redacted]"ស" ។

Scanned with CamScanner

ចូលមកបង្ហាញខ្លួនពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ ពីបទ "ការទិញពេស្យាចារកុមារ និងអំពើអាសប្រធាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ" ប្រព្រឹត្តនៅភូមិបន្ទាយចាស់ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៤ និងមាត្រា៤៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

បង្គាប់ឲ្យប្រធានមន្ទីរឃុំឃាំងខេត្តសៀមរាប ទទួលឃុំខ្លួនឈ្មោះនេះបណ្តោះអាសន្នឲ្យបានសម្រេច រហូតដល់មានបទបញ្ជាថ្មីសម្រេចផ្សេងពីនេះ ។

ដីកាសម្រេចមិនអនុញ្ញាតឱ្យនៅក្រៅឃុំជាបណ្តោះអាសន្នលេខ ១៤៦៨ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ ដែលមានខ្លឹមសារដូចតទៅ ៖

១.មិនអនុញ្ញាតឲ្យឈ្មោះ [redacted] PAUL MULROY ភេទប្រុស អាយុ៦៤ឆ្នាំ ជនជាតិអូស្ត្រាលី កាន់លិខិតឆ្លងដែនលេខ PEO391680 ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥ កើតនៅ LISMORE ប្រទេសអូស្ត្រាលី ទីលំនៅមុនពេលឃាត់ខ្លួននៅផ្ទះជួល [redacted] ខេត្តសៀមរាប កម្រិតវប្បធម៌បណ្ឌិត នៅលីវ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ។

ជាប់ចោទពីបទៈ "ការទិញពេស្យាចារកុមារ និងអំពើអាសប្រធាំងអនីតិជនអាយុក្រោម១៥ឆ្នាំ" ប្រព្រឹត្តនៅភូមិបន្ទាយចាស់ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៤ និងមាត្រា៤៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ហើយត្រូវបានឃុំខ្លួននៅមន្ទីរឃុំឃាំង ខេត្តសៀមរាប លេខឃុំខ្លួនៈ ៩៦៩ "ច"/២០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ ឲ្យនៅក្រៅឃុំជាបណ្តោះអាសន្នទេ ។

២.បង្គាប់ឲ្យក្រឡាបញ្ជីជូនដំណឹងទៅលោក [redacted] វណ្ណៈ ជាមេធាវីការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ [redacted] PAUL MULROY ដើម្បីទទួលដំណឹង ។

-បានឃើញ ពាក្យសុំប្តឹងអោយសភាស៊ើបសួរសម្រេចជំនួស លើពាក្យសុំអោយដោះលែងនៅក្រៅឃុំ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់លោក [redacted] មូស្សេន្នី ជាមេធាវីការពារសិទ្ធឱ្យជនត្រូវចោទ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌ៧២ សស ក្រ VII "ធ" ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលពាក្យសុំប្តឹងឱ្យសភាស៊ើបសួរសម្រេចជំនួស លើពាក្យសុំឱ្យដោះលែងនៅក្រៅឃុំ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់មេធាវី [redacted] មូស្សេន្នី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។



Scanned with CamScanner

២-មិនព្រមដោះលែងជនត្រូវចោទឈ្មោះ [redacted] PAUL MULROY ភេទប្រុស អាយុ៦៥ឆ្នាំ ជនជាតិអូស្ត្រាលី កាន់លិខិតឆ្លងដែនលេខ PE 0391680 ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥ កើតនៅ LISMORE ប្រទេសអូស្ត្រាលី អាសយដ្ឋានមុខពេលចាប់ខ្លួននៅផ្ទះជួលភូមិ [redacted] ខេត្តសៀមរាប កំរិតវប្បធម៌ បណ្ឌិត នៅលីវ។ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ដែលត្រូវបានចោទប្រកាន់ពីបទ ការទិញពេស្យាចារកុមារ និងអំពើអាសប្រតាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ ប្រព្រឹត្តនៅភូមិបន្ទាយចាស់ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០១៨ ឱ្យនៅក្រៅឃុំឡើយ ។

៣-សាលដីកានេះប្រកាសជាអសាធារណៈនាថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៣៧៧ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់លោក [redacted] មូស្សេទ្ធី ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] PAUL MULROY ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាសភាស៊ើបសួរនៃសាលាឧទ្ធរណ៍លេខ៧២ សស ក្រ VII "ធ" ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៨ ត្រង់ចំណុចនៃសេចក្តីសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូលធ្វើសេចក្តីសន្និដ្ឋានសុំថា៖ ជនត្រូវចោទឈ្មោះ [redacted] PAUL MULROY ត្រូវបានចោទពីបទៈ ការទិញពេស្យាចារ និងអំពើអាសប្រតាំង និងអនីតិជនអាយុក្រោម១៥ឆ្នាំ តាមមាត្រា ៣៤ និងមាត្រា៤៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ។ ដូចនេះសភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ មិនអនុញ្ញាតឱ្យនៅក្រៅឃុំនោះគឺស្របតាមមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌហើយ។

### តំណាងមហាអយ្យការ ស្នើក្រុមប្រឹក្សាជំនុំជម្រះសម្រេច៖

ទទួល បណ្តឹងសាទុក្ខលេខ៣៧៧ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់លោក [redacted] មូស្សេទ្ធី ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] PAUL MULROY ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធ ដោយខុសទៅនឹងគតិច្បាប់។

តម្កល់ សាលដីកាព្រហ្មទណ្ឌលេខ៧២ "សស.ក្រ.VII.ធ" ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

លោក [redacted] មូស្សេទ្ធី មេធាវីការពារជនត្រូវចោទធ្វើសេចក្តីសន្និដ្ឋានថា៖ ខ្លួនបានដាក់ពាក្យសុំបំពេញកិច្ចស៊ើបសួរ ៤ចំណុច តែចៅក្រមស៊ើបសួរបានសម្រេចតែចំណុចទី១ និងទី២ ចំណែកចំណុចទី៣ និងទី៤ មិនបានសម្រេចទេ គឺគាត់បានសម្រេចបិទការស៊ើបសួរ ហើយនៅក្នុងនីតិវិធីមានការរាំងស្ទះច្រើន។ ពាក់ព័ន្ធ និងការសុំនៅក្រៅឃុំនេះ



Scanned with CamScanner

ដូចមានក្នុងសេចក្តីសន្និដ្ឋានជាលាយលក្ខអក្សរ ដែលខ្ញុំបាទបានដាក់ជូនតុលាការ ចំពោះសាលដីកាសភាស៊ើបសួរសាលាឧទ្ធរណ៍ពុំបានបង្ហាញអំពីសំអាងហេតុ និងការយល់ឃើញរបស់គាត់ទេ ការសម្រេចរបស់សាលាឧទ្ធរណ៍ គ្រាន់តែបញ្ជាក់ថា ការមិនអនុញ្ញាតឱ្យជនត្រូវចោទនៅក្រៅឃុំដោយសារ ជនត្រូវចោទជាជនបរទេស និងដើម្បីការពារកុំឱ្យមានការគំរាមកំហែងសាក្សី បំផ្លាញភស្តុតាង និងរត់គេចខ្លួន និងប៉ះពាល់ដល់នីតិវិធីរបស់តុលាការ ទើបសម្រេចបន្តឃុំខ្លួនជនត្រូវចោទ។ ក្រោយពីពេលចាប់ខ្លួនកូនក្តីខ្ញុំ នគរបាលបានបញ្ជូនកូនក្តីខ្ញុំទៅមន្ទីពេទ្យភ្លាមដោយសារសម្ពាធឈាមកូនក្តីខ្ញុំឡើងខ្ពស់ និងត្រូវសង្គ្រោះបន្ទាន់រយៈពេល៣ថ្ងៃនៅមន្ទីពេទ្យ ។ ក្រោយពេលមកពីមន្ទីពេទ្យវិញ គាត់មានសេរីភាព បាននៅក្រៅឃុំកាលពីថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី២៧ ខែមិថុនា ទើបចៅក្រមស៊ើបសួរកោះហៅគាត់ ទើបសម្រេចឃុំខ្លួនគាត់ម្តងទៀត ចំណុចនេះហើយ បង្ហាញថារយៈពេល ៥ខែជាង ដែលកូនក្តីខ្លួននៅក្រៅឃុំ ប្រសិនបើកូនក្តីខ្លួន មានគំនិតចង់រត់គេច គឺរត់គេចបាត់ទៅហើយ ប៉ុន្តែកូនក្តីខ្លួនមិនបានរត់ទេ។ ជាក់ស្តែងកូនក្តីខ្លួនជនបរទេសពិតមែន ប៉ុន្តែគាត់គួរតែទទួលបានការអនុញ្ញាតឱ្យនៅក្រៅឃុំពីតុលាការ ផ្អែកលើស្ថានភាពជម្ងឺ និងវ័យ របស់គាត់។

សំណូមពរ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យកូនក្តីខ្លួនបាននៅក្រៅឃុំបណ្តោះអាសន្នដើម្បីកូនក្តីខ្លួនបានចេញមកព្យាបាលជម្ងឺ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៣៧៧ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់លោក [redacted] មូស្សេន្នី ជាមេធាវីការពារឱ្យជនត្រូវចោទឈ្មោះ [redacted] PAUL MULROY ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបានតាមមាត្រា៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចមិនព្រមដោះលែងជនត្រូវចោទឈ្មោះ [redacted] PAUL MULROY ភេទប្រុស អាយុ ៦៥ឆ្នាំ ជនជាតិអូស្ត្រាលី កាន់លិខិតឆ្លងដែនលេខ PE 0391680 ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥ កើតនៅ LISMORE ប្រទេសអូស្ត្រាលី អាសយដ្ឋានមុនពេលចាប់ខ្លួននៅ [redacted] ខេត្តសៀមរាប កម្រិតវប្បធម៌បណ្ឌិត នៅលីវ។ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រព្រឹត្តនៅភូមិបន្ទាយចាស់ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ ២០១៨ ឱ្យនៅក្រៅឃុំឡើយ ដោយយល់ឃើញ នៅក្នុងសំអាងហេតុត្រង់ចំណុចទី៣



Scanned with CamScanner

និងទី៤ នៃសាលដីកាព្រហ្មទណ្ឌលេខ៧២ ស.សក្រVII"ធ" ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ខ្លួននោះ តុលាការកំពូលពិនិត្យឃើញថា មានលក្ខណៈត្រឹមត្រូវស្របតាមមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដូច្នេះបណ្តឹងសាទុក្ខរបស់លោកមេធាវីការពារសិទ្ធិឲ្យជនត្រូវចោទខាងលើ ពុំមានមូលហេតុសមស្របតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ។

៣-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៧២ ស.សក្រVII "ធ" ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ ដែលបានសម្រេចមកនេះ ត្រឹមត្រូវតាមគតិច្បាប់។

**ហេតុដូច្នេះ**

**សម្រេច**

១-បដិសេធ បណ្តឹងសាទុក្ខលេខ៣៧៧ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់លោក [redacted] មូស្សេន្ទី មេធាវីការពារសិទ្ធិជនត្រូវចោទឈ្មោះ [redacted] PAUL MULROY ។

២-តម្កល់ សាលដីកាព្រហ្មទណ្ឌលេខ៧២ សសក្រVII"ធ" ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០។

Scanned with CamScanner